ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រស្ថិតិ
# សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០១៧

## អគ្គនាយកដ្ឋានគោលនយោបាយ
## សេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ
## ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ខែឧសភា ឆ្នាំ២០១៧

# មាតិកា


I. **សេចក្តីអធិប្បាយសង្ខេប** ........ 3

II. **ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ........ 8

**១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ** ........ 8

**២. សូចនាករតាមវិស័យ** ........ 10

២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ........ 10

២.៣. អត្រាប្តូរប្រាក់ ........ 11

២.៤. ហិរញ្ញវត្ថុសាធារណៈ ........ 12

២.៥. ឥណទាន និងរូបិយវត្ថុ ........ 16

២.៦. វិស័យពាណិជ្ជកម្ម ........ 17

២.៧. ការវិនិយោគឯកជន ........ 21

២.៨. វិស័យទេសចរណ៍ ........ 22

២.៩. វិស័យសំណង់ ........ 23

**៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ** ........ 24

III. **ឧបសម្ព័ន្ធ** ........ 27

**កំណត់សម្គាល់បច្ចេកទេស** ........ 31

# សេចក្តីអធិប្បាយសង្ខេប

សម្រាប់ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៧ នេះ អតិផរណាបានកំពុងមានកំណើនខ្ពស់បន្តិច ជាពិសេសផ្នែកអាហារ ខណៈអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក រក្សាបានស្ថេរភាពល្អ។ សម្រាប់វិស័យទ្រទ្រង់កំណើនសេដ្ឋកិច្ចវិញ ក្នុងនោះ*សំណើសុំវិនិយោគពីក្រៅប្រទេស និងសំណើសុំសាងសង់ (គិតជាទុនវិនិយោគ)* បានធ្លាក់ចុះខ្លាំងគួរឱ្យកត់សម្គាល់។ សម្រាប់ផលិតផលនាំចេញ តម្លៃនាំចេញផលិតផលកាត់ដេរ មានការថមថយកំណើន ប៉ុន្តែផលិតផលកសិកម្ម ជាពិសេសកៅស៊ូ មានកំណើនខ្ពស់ ទាំងបរិមាណនិងតម្លៃ យោងតាមកំណើនថ្លៃនិងតម្រូវការលើទីផ្សារបរទេស។ តម្រូវការឥណទានសំណង់និងអចលនទ្រព្យ និងការនាំចូលគ្រឿងបរិក្ខារសំណង់នៅបន្តមានកំណើនខ្ពស់ ទោះបីជាសំណើសុំសាងសង់បានធ្លាក់ចុះក្តី។ ផលិតកម្មរបស់សហគ្រាសធុនធំ សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញទៅទីផ្សារអន្តរជាតិ បានបន្តភាពរីកលូតលាស់។ ស្ថានភាពហិរញ្ញវត្ថុសាធារណៈបន្តរក្សាបាននូវស្ថេរភាព និងគ្រប់គ្រងដោយប្រសិទ្ធភាព គួបផ្សំនឹងការងើបឡើងវិញនៃកំណើនផលិតកម្មកសិកម្ម និងភ្ញៀវទេសចរអន្តរជាតិ។ **កំណើនកសិកម្ម និងឧស្សាហកម្មមិនមែនកាត់ដេរ រំពឹងថានឹងអាចជួយបំពេញបន្ថែមដល់ការថមថយកំណើនការនាំចេញផលិតផលកាត់ដេរ។**

**កំណើនសេដ្ឋកិច្ច**

**កំណើនសេដ្ឋកិច្ចសកលឆ្នាំ២០១៧ ត្រូវបានប៉ាន់ស្មានថាសម្រេចបាន ២,៧%**[1] ដោយសារការងើបឡើងវិញនៃឧស្សាហកម្មកម្មន្តសាល ស្ថេរភាពថ្លៃទំនិញប្រើប្រាស់នៅលើទីផ្សារអន្តរជាតិ និងកំណើនសេដ្ឋកិច្ចរបស់ប្រទេសអភិវឌ្ឍ ដែលរំពឹងថានឹងសម្រេចកំណើន ៤,៣%។

**សកម្មភាពកសិកម្មក្នុងត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនខ្ពស់ធៀបរយៈពេលដូចគ្នាឆ្នាំ ២០១៦** យោងតាមភាពប្រសើរឡើងនៃបរិមាណផលស្រូវ ដែលសម្រេចបាន ៩,៩ លានតោន (កើន ៧,៥%), ផ្ទៃដីដៀរជ័រកៅស៊ូ ១២៩.៦៦៦ ហិកតា (កើន ១៦,៨%), និងជលផល ១៤៩,៦ ពាន់តោន (៩,៧%)។

**សម្រាប់សកម្មភាពឧស្សាហកម្មក្នុងត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនថមថយធៀបរយៈពេលដូចគ្នាឆ្នាំ២០១៦។** តម្លៃនាំចេញផលិតផលកាត់ដេរ រួមមាន សម្លៀកបំពាក់ ស្បែកជើង និងវាយភ័ណ្ឌផ្សេងៗ សម្រេចបាន ៧.៤៥៤ ប៊ីលានរៀល ឬមានកំណើនប្រមាណ ៤,៦%[2]។ កំណើនថមថយរបស់ផលិតកម្មផ្សេងៗ ក្នុងនោះ សំណើសុំសាងសង់ (គិតជាទុនវិនិយោគ) មានតម្លៃ ១.៦៤៧ លានដុល្លារអាមេរិក ឬធ្លាក់ចុះខ្លាំងប្រមាណ ២២,២%។ កំណើនថមថយ

---

[1] A World Bank, January 2017. "Global Economic Prospects"

[2] ផលិតផលកាត់ដេរក្នុងត្រីមាសទី១ ឆ្នាំ២០១៦ ធៀបរយៈពេលដូចគ្នា ឆ្នាំ២០១៥ មានកំណើន ១៤%។

នៅត្រីមាសទី១ ឆ្នាំ២០១៧ ក៏សង្កេតឃើញមានក្នុងការចុះបញ្ជីសហគ្រាសស្បៀង ភេសជ្ជៈ និងថ្នាំជក់[3] ផងដែរ។

**សកម្មភាពសេវាកម្មក្នុងត្រីមាសទី១ ឆ្នាំ២០១៧ មានភាពល្អប្រសើរ ធៀបរយៈពេលដូចគ្នា ឆ្នាំ២០១៦** យោងតាមទំហំពាណិជ្ជកម្មនាំចេញ-នាំចូល ដែលមានកំណើនប្រមាណ ១០% ការរឹតបន្តឹងកម្ចីឥណទាន[4] និងការរីកលូតលាស់នៃកំណើនអ្នកដំណើរអន្តរជាតិឆ្លងកាត់ប្រទេសកម្ពុជា។

**ស្ថានភាពហិរញ្ញវត្ថុសាធារណៈ**

យោងតាមទិន្នន័យបណ្ដោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ ការប្រមូលចំណូលចរន្តទូទាំងប្រទេស ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ អនុវត្តបានចំនួន ៤.២៦១ ប៊ីលានរៀល (កើន ២១,៣%) ធៀបរយៈពេលដូចគ្នា ឆ្នាំ២០១៦។ លើចំនុចនេះ **ក).** ចំណូលពន្ធដារ កើន ៥១,៥% **ខ).** ចំណូលមិនមែនសារពើពន្ធ កើន ៣៧,៤% និង **គ).** ចំណូលគយ និងរដ្ឋាករ ថយចុះ ៦,៣%។

យោងតាមទិន្នន័យបណ្ដោះអាសន្នពីអគ្គនាយកដ្ឋានរតនាគារជាតិ ចំណាយសរុបក្នុងប្រទេស ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ អនុវត្តបាន ៣.០៩១ ប៊ីលានរៀល (កើន ៣០,៦%) ធៀបរយៈពេលដូចគ្នា ឆ្នាំ២០១៦។ ក្នុងន័យនេះ ចំណាយចរន្តអនុវត្តបានប្រមាណ ២.២៣២ ប៊ីលានរៀល (កើន ២៨%) និងចំណាយមូលធនអនុវត្តបាន ៨៥៩ ប៊ីលានរៀល (កើន ៣៧,៨%)។

**ជាលទ្ធផល អតិរេកតុល្យភាពចរន្តនៃប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ មានចំនួន ១៩៥៩ ប៊ី. លានរៀល និងឱនភាពតុល្យភាពទូទៅ មានចំនួន ១១០០ ប៊ីលានរៀល។.**

**អតិផរណា និង អត្រាប្តូរប្រាក់**

អត្រាអតិផរណាប្រចាំឆ្នាំក្នុងត្រីមាសទី១ ឆ្នាំ២០១៧ នេះ មានជាមធ្យម ៣,៣% ទោះជាកើនខ្ពស់បន្តិចពី ១,៥% នៅត្រីមាស ទី១ ឆ្នាំ២០១៦។ **កំណើនទ្វេរដងនេះ ដោយសារការបន្តកើនឡើងខ្ពស់នៃអតិផរណាសម្លៀកបំពាក់ និងស្បែកជើង (៤,២%) និងអាហារ-ភេសជ្ជៈមិនមានជាតិស្រវឹង (៥,៨%)**។ របាយការណ៍ FAO ក៏បង្ហាញផងដែរថា សន្ទស្សន៍ថ្លៃអាហារសកល ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនខ្ពស់ ១៥,៩% ធៀបត្រីមាសទី១ ឆ្នាំ២០១៦ ដែលមាន

[3] កំណើននៃការចុះបញ្ជីសហគ្រាសធុនធំ ផ្នែកស្បៀង ភេសជ្ជៈ និងថ្នាំជក់ បានថមថយពី ១១,២% ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ មកនៅត្រឹម ៧,៣% ក្នុងត្រីមាសទី១ ឆ្នាំ២០១៧។ ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម ផ្នែកស្បៀង ភេសជ្ជៈ និងថ្នាំជក់ មានកំណើនទាប។

[4] ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ បានបន្ថយកំណើនពី ២៦% ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ មកនៅត្រឹម ១៤% ក្នុងត្រីមាសទី១ ឆ្នាំ២០១៧។ ខណៈការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ បានបន្ថយកំណើនពី ៤៣% ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ មកនៅត្រឹម ៤% ក្នុងត្រីមាសទី១ ឆ្នាំ២០១៧។

អត្រា (-១៤,៥%)។ **គួរកត់សម្គាល់ផងដែរថា ថ្លៃប្រេងឥន្ធនៈក្នុងស្រុកកំពុងមានកំណើនខ្ពស់ស្របគ្នានឹងកំណើនថ្លៃប្រេងឆៅ ពិភពលោកផងដែរ។**

អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ បានបន្តមានស្ថេរភាពល្អ ក្នុងកម្រិតជាមធ្យមប្រមាណ ៤.០០០ រៀល (+/-១%)។ **ធនាគារជាតិកម្ពុជា បានកំពុងអនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដោយធ្វើអន្តរាគមលើទីផ្សារប្តូរប្រាក់ដើម្បីគ្រប់គ្រងនិងរក្សាស្ថិរភាពអត្រាប្តូរប្រាក់។** គិតត្រឹមខែមីនា ឆ្នាំ២០១៧នេះ ទុនបម្រុងជារូបិយប័ណ្ណបរទេសបានកើនឡើងដល់ ៧.១៥៣ លានដុល្លារ។ ក្នុងរយៈពេល៣ខែ ឆ្នាំ២០១៧នេះ ធនាគារជាតិបានធ្វើការទិញចូលនូវប្រាក់ដុល្លារចំនួន ១៥៩លានដុល្លារ។

## ប្រតិបត្តិការ ហិរញ្ញវត្ថុ

អត្រាការប្រាក់ឥណទានរបស់ធនាគារពាណិជ្ជបានថយចុះគួរកត់សម្គាល់ក្នុងដើមឆ្នាំ២០១៧នេះ, គិតត្រឹមខែមីនា ឆ្នាំ២០១៧ អត្រាការប្រាក់របស់ធនាគារពាណិជ្ជ ចំពោះឥណទានជាប្រាក់រៀលស្មើនឹង ១៦,០៥% និងឥណទានជាប្រាក់ដុល្លារស្មើនឹង ១១,៦៧%។ រីឯអត្រាការប្រាក់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (គ្រឹះស្ថាន៣ធំជាងគេ) ពុំមានការប្រែប្រួលគួរកត់សម្គាល់ទេ។ កត្តាកំណត់អត្រាការប្រាក់សំខាន់ៗនៃគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា ដូចជាចំណាយលើប្រភពមូលទុន ប្រតិបត្តិការអាជីវកម្ម ឥណទានមិនដំណើរការ អតិផរណា និងប្រាក់ចំណេញ។

**ការផ្គត់ផ្គង់រូបិយវត្ថុ (M2) បានឆ្លុះបញ្ចាំងពីកំណើនសកម្មភាពសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។** ជាក់ស្តែង រូបិយវត្ថុទូទៅ (M2) ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ នេះ មានកំណើន ១៩% ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៦ ហើយកំណើននេះ ប្រហាក់ប្រហែលនឹងអត្រាកំណើនជាមធ្យមក្នុងរយៈពេល ០២ ឆ្នាំចុងក្រោយនេះ។ ឥណទានផ្តល់ដោយធនាគារពាណិជ្ជក្នុងត្រីមាសទី១ មានកំណើន ១៣,៧% ក្នុងនោះ **ក).** ឥណទានទៅគ្រឹះស្ថានហិរញ្ញវត្ថុ បានធ្លាក់ចុះ ៣៣% **ខ).** ឥណទានទៅគ្រឹះស្ថានមិនមែនហិរញ្ញវត្ថុនានា បានកើន ១១% **គ).** ឥណទានសម្រាប់តម្រូវការផ្ទាល់ខ្លួន បានកើន ៤១%។ **ប្រតិបត្តិការហិរញ្ញវត្ថុកម្ពុជា គិតត្រឹមត្រីមាសទី១ ឆ្នាំ២០១៧ រក្សាបានស្ថេរភាពល្អប្រសើរ ស្របគ្នានឹងការរីតបណ្តឹងឥណទានប្រកបដោយប្រសិទ្ធភាព និងប្រុងប្រយ័ត្នខ្ពស់ តាមរយៈស្ថានភាពកំណើនភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP) ត្រឹមកម្រិត ៦៧,៧%**។

## ពាណិជ្ជកម្មក្រៅប្រទេស

ចំពោះសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស **ការនាំចេញសរុបរបស់កម្ពុជា នៅត្រីមាសទី១ ឆ្នាំ២០១៧ សម្រេចបាន ១០.១៦៥ ប៊ីលានរៀល ឬមានកំណើន ៥,៣%** ក្នុងនោះផ្នែកកាត់ដេរ

និងស្បែកជើង សម្រេចបាន ៧.៤៥៤ ប៊ីលានរៀល, ផលិតផលឧស្សាហកម្ម ១.៨៦៥ ប៊ីលានរៀល, ផលិតផលកសិកម្ម ៨៤៦ ប៊ីលានរៀល, និងគ្រឿងបង្គុំ ៥១៨ ប៊ីលានរៀល។ **ជាការកត់សម្គាល់ធៀបត្រីមាសទី១ ឆ្នាំ២០១៦ ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើងដែលរួមចំណែកប្រមាណ ៧៣,៣% នៃតម្លៃនាំចេញសរុប មានកំណើនទាបត្រឹម ៤,៦% ខណៈតម្លៃនាំចេញផលិតផលឧស្សាហកម្មដ៏ទៃទៀត បានធ្លាក់ចុះ ៥,៥%។ ទោះយ៉ាងណាក្តី ក៏តម្លៃនៃការនាំចេញផលិតផលកសិកម្មមានកំណើនប្រមាណ ៥៣,២%**។

សម្រាប់ការនាំចេញទំនិញទៅទីផ្សារបរទេសនៅត្រីមាសទី១ ឆ្នាំ២០១៧ ធៀបរយៈពេលដូចគ្នាឆ្នាំ២០១៦ ក្នុងនោះ**ទីផ្សារសហគមន៍អឺរ៉ុប** សម្រេចបាន ៣.៩០៤ ប៊ីលានរៀល ឬមានកំណើន ១,១% **ទីផ្សារអាមេរិក** មានទំហំទឹកប្រាក់ ២.១៥២ ប៊ីលានរៀល ឬមានកំណើនខ្ពស់ ១០,៨% និង**ទីផ្សារដ៏ទៃទៀត ដោយមិនរួមបញ្ចូលទីផ្សារជប៉ុន និងអាស៊ាន** មានទំហំទឹកប្រាក់ ២១.៥៦ ប៊ីលានរៀល ឬមានកំណើនខ្ពស់ ១៣,៧%។

នៅត្រីមាសទី១ ឆ្នាំ២០១៧ **ការនាំចូលមុខទំនិញគ្រប់មុខ មានទំហំទឹកប្រាក់ ១២.៧៦៣ ប៊ីលានរៀល ឬមានកំណើន ១៣,១%** ក្នុងនោះ **ទំនិញវាយនភណ្ឌ និងសម្លៀកបំពាក់** ៣.៣៦៨ ប៊ីលានរៀល (កំណើន ៩,៥%), **បរិក្ខារសំណង់** ៦១៧ ប៊ីលានរៀល (កំណើន ២៨,៩%), **ប្រេងឥន្ធនៈ** ១.០១១ ប៊ីលានរៀល (ធ្លាក់ចុះ ១៦,៨%), **និងមុខទំនិញផ្សេងៗដែលមានសមាមាត្រ ៤០,២% នៃការនាំចូលសរុប** មានទំហំទឹកប្រាក់ ៥.១៣៣ ប៊ីលានរៀល (កំណើន ៣០,១%)។

**អតិរេកជញ្ជីងទូទាត់នៅត្រីមាសទី១ ឆ្នាំ២០១៧ ស្មើប្រមាណ ២,៩% នៃ ផ.ស.ស (ព្យាករណ៍ឆ្នាំ២០១៧) ឬបានកើនពី ២% នៅត្រីមាសទី១ ឆ្នាំ២០១៦ ដោយសារកំណើនលំហូរចូលនៃមូលធនវិនិយោគ។**

## ការវិនិយោគឯកជន

ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុញ្ញាតលើសំណើសុំវិនិយោគសរុបទូទាំងប្រទេស បានចំនួន ២១ គម្រោង ឬ ១៣១ លានដុល្លារអាមេរិក។ **ធៀបរយៈពេលដូចគ្នា ឆ្នាំ២០១៦ គិតជាចំនួនគម្រោង បានធ្លាក់ចុះ ៤៣,២% ឬគិតជាទុនវិនិយោគបានធ្លាក់ចុះ ៨៦,៣%**។ ទុនវិនិយោគលើវិស័យកសិកម្មសម្រាប់ត្រីមាសទី១ មាន ៨ លានដុល្លារអាមេរិក ឬបានថយចុះ ៧៩,១%។ ដោយឡែកទុនវិនិយោគលើវិស័យឧស្សាហកម្មមាន ១១៦ លានដុល្លារអាមេរិក ឬបានថយចុះ ១៤%។ **ទោះជាយ៉ាងណាក្តី សកម្មភាពវិនិ**

យោគក្រៅប្រទេស រំពឹងថានឹងហក់ឡើងមកវិញ តាមរយៈគម្រោងដែលនឹងទទួលបានការអនុញ្ញាតបន្តបន្ទាប់។

**ទេសចរណ៍**

**សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៧ នេះ កម្ពុជាទទួលបានអ្នកដំណើរប្រមាណជា ១.៥០៣ លាននាក់ ឬកំណើន ១១,៩% ធៀបត្រីមាសទី១ ឆ្នាំ២០១៦។** ការកើនឡើងនេះ ដោយសារ**អ្នកដំណើរមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក** មានកំណើន ១៨,៤% **សហភាពអឺរ៉ុប និងអាមេរិក**មានកំណើន ១១,៥% ដូចគ្នា។

**វិស័យសំណង់**

ក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ **បានអនុម័តលើសំណើអនុញ្ញាតសាងសង់ ចំនួន ៧៨៦ គម្រោង ឬមានកំណើន ៦៦,២%** ធៀបត្រីមាសទី១ ឆ្នាំ២០១៦។ គម្រោងទាំងអស់នេះ បើគិតផ្ទៃក្រឡាសរុប មានប្រមាណ ២ លានម៉ែត្រការ៉េ ឬបានថយចុះ ៤៥,៤% ធៀបត្រីមាសទី១ ឆ្នាំ២០១៦ **ដោយសារសំណង់ពាណិជ្ជកម្ម ដែលធ្លាប់មានសមាមាត្រ ៥៧,២% នៃក្រឡាផ្ទៃសាងសង់សរុប នៅត្រីមាសទី១ ឆ្នាំ២០១៦ បានថយមកនៅត្រឹមតែ ៧,៣% ប៉ុណ្ណោះ នៅត្រីមាសទី១ ឆ្នាំ២០១៧។**

# ស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ១. សូចនាករសេដ្ឋកិច្ចសំខាន់ៗ

*តារាង 1 ÷ ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗ*

| | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **សូចនាករមូលដ្ឋាន** | | | | |
| អតិផរណា (កំណើនប្រចាំឆ្នាំ) | % | 1.1% | 2.0% | 4.2% |
| អតិផរណា (កំណើនមធ្យមប្រចាំឆ្នាំ) | % | 3.3% | 1.5% | 3.3% |
| អត្រាប្តូរប្រាក់រៀល/ ដុល្លារ (មធ្យមប្រចាំឆ្នាំ) | រៀល | 4,043 | 4,023 | 4,016 |
| **ហិរញ្ញវត្ថុសាធារណៈ** | | | | |
| ចំណូលចរន្ត | ប៊ីលានរៀល | 2,638 | 3,533 | 4,262 |
| ចំណាយចរន្ត | ប៊ីលានរៀល | 1,515 | 1,743 | 2,232 |
| តុល្យភាពថវិកាចរន្ត | ប៊ីលានរៀល | 1,123 | 1,790 | 2,030 |
| **ឥណទាន និងរូបិយវត្ថុ** | | | | |
| រូបិយវត្ថុទូទៅ (% នៃ ផសស) | % | 59.5% | 63.3% | 67.7% |
| កំណើនរូបិយវត្ថុទូទៅ | % | 24.2% | 16.7% | 18.8% |
| ប្រាក់បញ្ញើជារូបិយប័ណ្ណ (% នៃរូបិយវត្ថុទូទៅ) | % | 82.4% | 83.9% | 84.5% |
| **ពាណិជ្ជកម្មអន្តរជាតិ** | | | | |
| ទំនិញនាំចូល | ប៊ីលានរៀល | 8,756 | 9,652 | 10,165 |
| ទំនិញនាំចេញ | ប៊ីលានរៀល | 10,983 | 11,280 | 12,763 |
| តុល្យភាពពាណិជ្ជកម្ម | ប៊ីលានរៀល | (2,227) | (1,629) | (2,597) |
| **វិនិយោគឯកជន** | | | | |
| គម្រោង | ចំនួន | 37 | 37 | 21 |
| អចលនទ្រព្យ | លានដុល្លារ | 2,873 | 955 | 131 |
| បង្កើតការងារ | ពាន់នាក់ | 45,562 | 43,345 | 33,825 |
| **ទេសចរណ៍** | | | | |
| អ្នកធ្វើដំណើរឆ្លងកាត់ប្រទេសកម្ពុជា | ពាន់នាក់ | 1,308 | 1,342 | 1,503 |
| ក្នុងនោះ អ្នកទេសចរ | ពាន់នាក់ | 1,190 | 1,188 | 1,353 |

| | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **វិស័យសំណង់** | | | | |
| គម្រោង | ចំនួន | 368 | 473 | 786 |
| ក្រឡាផ្ទៃ | ម២ | 1,412,314 | 3,799,404 | 2,073,040 |
| តម្លៃសាងសង់ | លានដុល្លារ | 445 | 1,647 | 1,282 |
| **ថ្លៃទំនិញលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)** [5] | | | | |
| អង្ករ | ដុល្លារ/តោន | 410 | 384 | 358 |
| ប្រេងឆៅ (Brent) -- បារ៉ែល | ដុល្លារ/បារ៉ែល | 56 | 39 | 52 |
| កៅស៊ូ | ដុល្លារ/តោន | 1,735 | 1,447 | 2,350 |
| មាស | ដុល្លារ/អោន | 1,074 | 1,366 | 1,351 |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, វិទ្យាស្ថានជាតិស្ថិតិ, និងធនាគារជាតិ

[5] គឺជាថ្លៃទំនិញចុងត្រីមាស

# ២. សូចនាករតាមវិស័យ

## ២.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

*តារាង 2 ៖ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (មធ្យមប្រចាំត្រីមាសទី១) -- ឆ្នាំ២០១៧*

| សូចនាករ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **មុខទំនិញគ្រប់មុខ** | **158.6** | **160.9** | **166.23** |
| អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង | 183.4 | 190.8 | 201.95 |
| ភេសជ្ជៈមានជាតិស្រវឹង និង ថ្នាំជក់ | 137.8 | 145.3 | 157.58 |
| សម្លៀកបំពាក់ និង ស្បែកជើង | 130.5 | 135.9 | 141.47 |
| ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈដទៃទៀត | 130.0 | 125.6 | 124.62 |
| គ្រឿងសង្ហារឹម សម្ភារប្រើប្រាស់ និងការថែទាំ | 141.7 | 144.3 | 148.89 |
| សុខាភិបាល | 127.4 | 128.5 | 131.87 |
| ការដឹកជញ្ជូន | 126.4 | 115.7 | 109.36 |
| គមនាគមន៍ | 68.5 | 68.1 | 68.31 |
| ការកំសាន្ត និងវប្បធម៌ | 112.0 | 114.5 | 118.10 |
| ការសិក្សា | 159.4 | 159.6 | 160.08 |
| ភោជនីយដ្ឋាន | 222.3 | 233.2 | 241.20 |
| ទំនិញ និង សេវាកម្មផ្សេងៗ | 142.0 | 138.2 | 139.76 |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

*រូបភាព 1 ៖ ស្ថានភាពអតិផរណា (ប្រែប្រួលមធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៧*




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ

## ២.៣. អត្រាប្តូរប្រាក់

*តារាង 3 ÷ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៧*

| អត្រាប្តូរប្រាក់ចុងខែ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| 2011 | 4,043 | 4,045 | 4,095 | 4,065 |
| 2012 | 4,030 | 4,038 | 4,056 | 4,007 |
| 2013 | 3,995 | 4,032 | 4,062 | 4,020 |
| 2014 | 3,994 | 4,026 | 4,060 | 4,070 |
| 2015 | 4,043 | 4,056 | 4,092 | 4,051 |
| 2016 | 4,023 | 4,055 | 4,094 | 4,042 |
| 2017 | 4,016 | | | |

ប្រភព: ធនាគារជាតិនៃកម្ពុជា

*រូបភាព 2 ÷ ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិក (ប្រែប្រួលមធ្យមប្រចាំត្រីមាស) -- ឆ្នាំ២០១៧*




ប្រភព: ធនាគារជាតិនៃកម្ពុជា

## ២.៤. ហិរញ្ញវត្ថុសាធារណៈ

*តារាង 4 ÷ តារាងប្រតិបត្តិការហិរញ្ញវត្ថុ (TOFE)*

| លានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **I. ចំណូលក្នុងប្រទេស** | **2,665,563** | **3,533,094** | **4,261,929** |
| **១. ចំណូលចរន្ត** | **2,655,766** | **3,514,749** | **4,261,929** |
| ***ក. ចំណូលសារពើពន្ធ*** | **2,448,375** | **3,255,469** | **3,905,762** |
| **១. ពន្ធផ្ទាល់** | **598,708** | **897,252** | **1,276,340** |
| ពន្ធលើប្រាក់បៀវត្ស | 113,506 | 135,257 | 251,485 |
| ពន្ធលើប្រាក់ចំណេញ | 450,137 | 711,710 | 949,593 |
| ពន្ធលើផលទុនដីធ្លី និងផ្ទះសំបែង | 35,065 | 50,286 | 75,262 |
| **២. ពន្ធប្រយោល** | **1,413,889** | **1,818,084** | **2,173,684** |
| ពន្ធលើផលរបរ | 6,330 | 392 | 19 |
| អាករលើតម្លៃបន្ថែម | 831,635 | 986,098 | 1,262,069 |
| អាករពិសេស | 536,798 | 816,746 | 887,952 |
| ចំណូលពន្ធផ្សេងៗទៀត | 39,125 | 14,848 | 23,644 |
| **៣. ពន្ធពាណិជ្ជកម្មក្រៅប្រទេស** | **435,778** | **540,133** | **455,738** |
| ពន្ធនាំចូល | 387,529 | 533,633 | 446,985 |
| ពន្ធនាំចេញ | 30,476 | 6,422 | 8,666 |
| ពន្ធនាំចេញផ្សេងៗទៀត | 17,773 | 77 | 87 |
| ***ខ. ចំណូលមិនមែនសារពើពន្ធ*** | **207,391** | **259,281** | **356,168** |
| ចំណូលពីនេសាទ | 766 | 286 | 549 |
| ចំណូលពីព្រៃឈើ | 0 | 5,659 | 0 |
| ចំណូលពីការជួលសហគ្រាស | 54 | 0 | 5 |
| ចំណូលពីអាកាសចរស៊ីវិល | 17,404 | 23,299 | 22,874 |
| ចំណូលពីសម្បទាន | 33,346 | 16,089 | 80,066 |
| ចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 2,309 | 2,575 | 1,571 |
| អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ) | 101,419 | 120,861 | 135,970 |
| ផលពីការបង់សិទ្ធិប្រលង | 6,477 | 1,549 | 991 |
| ចំណូលពីការជួល | 2,262 | 2,986 | 2,456 |
| ចំណូលមិនមែនពន្ធផ្សេងៗ | 43,353 | 85,976 | 111,686 |
| **២. ចំណូលមូលធន** | **9,797** | **18,345** | **0** |
| ការប្រមូលមកវិញនៃឥណទាន | 9,797 | 18,345 | 0 |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| លានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **II. ចំណាយសរុប** | **2,097,792** | **2,366,666** | **3,090,849** |
| **១. ចំណាយចរន្ត** | **1,438,879** | **1,743,381** | **2,231,882** |
| ***ក. ការពារ និងសន្តិសុខជាតិ*** | **521,752** | **566,666** | **799,607** |
| ***ខ. រដ្ឋបាលស៊ីវិល*** | **840,438** | **1,066,810** | **1,314,095** |
| ***គ. ចំណាយការប្រាក់*** | **76,689** | **109,905** | **118,179** |
| **២. ចំណាយមូលធន** | **658,914** | **623,285** | **858,968** |
| ហិរញ្ញប្បទានក្នុងស្រុក | 207,045 | 237,190 | 184,113 |
| ពីចំណូលក្នុងស្រុក | 207,045 | 237,190 | 184,113 |
| ពីជំនួយជាទំនិញ | 0 | 0 | 0 |
| ហិរញ្ញប្បទានពីបរទេស | 451,868 | 386,095 | 674,855 |
| កែតម្រូវ | 133,215 | (129,996) | (70,869) |
| ***និនភាពចរន្ត (សាច់ប្រាក់)*** | **1,350,102** | **1,641,372** | **1,959,179** |
| ***និនភាពទូទៅ (សាច់ប្រាក់)*** | **700,985** | **1,036,433** | **1,100,211** |
| **III. ហិរញ្ញប្បទាន** | **(683,212)** | **(1,036,433)** | **(1,100,211)** |
| **១. ហិរញ្ញប្បទានពីបរទេស** | **373,405** | **265,502** | **598,470** |
| ទ្រទ្រង់ថវិកា | 0 | 0 | 0 |
| ជំនួយគម្រោងអភិវឌ្ឍន៍ | 434,345 | 386,816 | 699,074 |
| រំលោះបំណុលបរទេស | (60,939) | (121,314) | (100,604) |
| **២. ហិរញ្ញប្បទានក្នុងស្រុក** | **(2,464,992)** | **(2,092,747)** | **(352,803)** |
| បញ្ញើរដ្ឋាភិបាល | (2,489,300) | (1,663,660) | (7,219) |
| វិស័យឯកជន | 278,710 | (405,848) | (332,264) |
| ផ្សេងៗ | (254,401) | (23,238) | (13,320) |
| **៣. ប្រតិបត្តិការកំពុងដំណើរការ** | **1,408,374** | **790,812** | **(1,345,878)** |

ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 5 ÷ ចំណាយចរន្តតាមក្រសួង

| លានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **សរុបចំណាយជាប្រចាំ** | **1,514,632** | **1,743,381** | **2,231,882** |
| **១.រដ្ឋបាលទូទៅ** | **398,999** | **498,666** | **563,567** |
| ព្រះបរមរាជវាំង | 15,468 | 14,593 | 19,458 |
| រដ្ឋសភា | 45,744 | 34,781 | 58,607 |
| ព្រឹទ្ធសភា | 28,120 | 21,724 | 22,740 |
| ក្រុមប្រឹក្សាធម្មនុញ្ញ | 2,216 | 2,294 | 2,930 |
| ទីស្តីការគណៈរដ្ឋមន្ត្រី | 44,923 | 78,870 | 70,046 |
| ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | 0 | 0 | 195 |
| ក្រសួងមហាផ្ទៃ-រដ្ឋបាលទូទៅ | 14,542 | 14,247 | 19,405 |
| ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | 2,785 | 3,156 | 3,253 |
| ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 20,907 | 21,842 | 15,660 |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 201,970 | 282,686 | 315,222 |
| ក្រសួងផែនការ | 4,507 | 5,629 | 9,182 |
| ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 6,924 | 7,712 | 11,294 |
| គ.ជ.ប | 947 | 2,093 | 3,700 |
| អាជ្ញាធរសវនកម្មជាតិ | 1,478 | 1,210 | 1,341 |
| អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ | 6,514 | 5,159 | 6,498 |
| ក្រសួងមុខងារសាធារណៈ | 1,954 | 2,669 | 4,036 |
| **២.ការពារ និងសន្តិសុខ** | **527,561** | **575,498** | **812,573** |
| ក្រសួងការពារជាតិ | 331,971 | 311,673 | 510,654 |
| ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ | 189,781 | 254,993 | 288,954 |
| ក្រសួងយុត្តិធម៌ | 5,810 | 8,831 | 12,966 |
| **៣.រដ្ឋបាលសង្គមកិច្ច** | **452,348** | **555,242** | **719,140** |
| ក្រសួងព័ត៌មាន | 9,517 | 9,360 | 7,073 |
| ក្រសួងសុខាភិបាល | 50,992 | 66,059 | 93,049 |
| ក្រសួងអប់រំ យុវជន និងកីឡា | 223,906 | 280,942 | 375,270 |
| ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | 5,612 | 6,309 | 8,293 |
| ក្រសួងបរិស្ថាន | 4,629 | 4,079 | 5,888 |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 143,393 | 169,602 | 203,153 |
| ក្រសួងធម្មការ និងកិច្ចការសាសនា | 2,633 | 4,014 | 7,163 |
| ក្រសួងកិច្ចការនារី | 2,572 | 3,825 | 4,700 |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 9,093 | 11,051 | 14,552 |

| លានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **៤.រដ្ឋបាលសេដ្ឋកិច្ច** | **112,975** | **111,185** | **97,654** |
| រដ្ឋ. ដ្ឋានអាកាសចរណ៍ស៊ីវិល | 1,985 | 1,761 | 2,437 |
| ក្រសួងរ៉ែ និងថាមពល | 1,594 | 2,239 | 3,469 |
| ក្រសួងពាណិជ្ជកម្ម | 12,536 | 13,251 | 10,975 |
| ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 15,646 | 16,932 | 21,614 |
| ក្រសួងអភិវឌ្ឍន៍ជនបទ | 9,275 | 5,752 | 6,735 |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | 3,982 | 3,283 | 4,464 |
| ក្រសួងសាធារណៈការ និងដឹកជញ្ជូន | 52,310 | 53,200 | 23,013 |
| ក្រសួងទេសចរណ៍ | 8,108 | 7,111 | 12,892 |
| ក្រសួងធនធានទឹក និងឧតុនិយម | 5,042 | 4,506 | 6,349 |
| ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | 2,496 | 3,151 | 5,707 |
| **ចំណាយផ្សេងៗ** | **22,749** | **2,791** | **38,947** |

*ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## *រូបភាព 3 ÷ ចំណាយចរន្តបែងចែកតាមវិស័យ*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*រូបភាព 4÷ ស្ថានភាពតុល្យភាពថវិកាចរន្ត (គិតជាលានរៀល)*




ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ២.៥. ឥណទាន និងរូបិយវត្ថុ

*តារាង 6÷ ស្ថានភាពរូបិយវត្ថុ*

| (ប៊ីលានរៀល) | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **ទ្រព្យសកម្មបរទេសសុទ្ធ** | **26,823** | **29,323** | **36,490** |
| ទ្រព្យសកម្មបរទេស | 35,265 | 43,144 | 51,537 |
| ទ្រព្យអកម្មបរទេស | (8,442) | (13,821) | (15,047) |
| **ទ្រព្យសកម្មក្នុងស្រុកសុទ្ធ** | **16,861** | **21,661** | **24,057** |
| ឥណទានក្នុងស្រុក | 32,695 | 40,006 | 47,567 |
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | (5,064) | (7,621) | (9,819) |
| ផ្នែកមិនមែនរដ្ឋាភិបាល | 37,759 | 47,627 | 57,386 |
| **ទ្រព្យសកម្មផ្នែកផ្សេងៗ** | **(15,834)** | **(18,344)** | **(23,510)** |
| ប្រាក់បញ្ញើហាមឃាត់ | (930) | (1,067) | (1,358) |
| មូលធន និង ធនបំរុង | (13,912) | (16,276) | (19,361) |
| ផ្សេងៗ | (993) | (1,002) | (2,792) |

| (ប៊ីលានរៀល) | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **រូបិយវត្ថុទូទៅ (M2)** | **43,684** | **50,984** | **60,547** |
| រូបិយវត្ថុ (M1) | 6,628 | 6,811 | 7,525 |
| *រូបិយវត្ថុក្រៅធនាគារ* | 5,884 | 6,147 | 6,835 |
| *ប្រាក់បញ្ញើចរន្ត* | 744 | 663 | 690 |
| រូបិយវត្ថុផ្សេងៗ | 37,056 | 44,173 | 53,023 |
| *ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ* | 1,065 | 1,395 | 1,843 |
| *ប្រាក់បញ្ញើជារូបិយប័ណ្ណ (បរទេស)* | 35,991 | 42,778 | 51,179 |

ប្រភព: ធនាគារជាតិកម្ពុជា

## ២.៦. វិស័យពាណិជ្ជកម្ម

*តារាង 7÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាបរិមាណ)*

| មុខទំនិញ | ឯកត្តា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| ថ្នាំពេទ្យ | ពាន់តោន | 5 | 5 | 5 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | ពាន់កាតុង | 8,047 | 9,352 | 11,053 |
| ស្ករស និងប៊ីចេង | ពាន់តោន | 16 | 23 | 36 |
| ប្រេងឆា និងអាហារផ្សេងៗ | ពាន់កាតុង | 36 | 66 | 64 |
| សម្ភារសំណង់ | ពាន់តោន | 644 | 560 | 612 |
| អេឡិចត្រូនិច | ពាន់គ្រឿង | 6 | 108 | 47 |
| វាយនភ័ណ្ឌ និងសម្លៀកបំពាក់ | ពាន់តោន | 122 | 146 | 151 |
| ទោចក្រ- យានយន្ត | ពាន់គ្រឿង | 148 | 179 | 136 |
| គ្រឿងបន្លាស់យានយន្ត | ពាន់តោន | 3 | 2 | 2 |
| បរិក្ខារត្រជាក់ | ពាន់គ្រឿង | 49 | 36 | 31 |
| មាស | គីឡូក្រាម | 6 | 28 | 2 |
| ប្រេងឥន្ធនៈ | ពាន់តោន | 464 | 528 | 708 |
| ជីកសិកម្ម | ពាន់តោន | 62 | 87 | 152 |
| ផ្សេងៗ | ពាន់តោន | 799 | 551 | 1,328 |

ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 5 ÷ ការនាំចូលប្រេងឥន្ធនៈ បរិក្ខារសំណង់ និងវាយភ័ណ្ឌ និងសម្លៀកបំពាក់ (ពាន់តោន)




ប្រភពៈ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 8 ÷ ការនាំចូលតាមមុខទំនិញសំខាន់ៗ (គិតជាប៊ីលានរៀល)

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ថ្នាំពេទ្យ | 126 | 139 | 143 |
| ភេសជ្ជៈ គ្រឿងស្រវឹង និងបារី | 379 | 453 | 439 |
| ស្ករស និងប៊ីចេង | 28 | 31 | 59 |
| ប្រេងឆា និងអាហារផ្សេងៗ | 156 | 228 | 287 |
| សម្ភារសំណង់ | 401 | 478 | 617 |
| អេឡិចត្រូនិច | 3 | 13 | 6 |
| វាយនភ័ណ្ឌ | 2,765 | 3,076 | 3,368 |
| ទោចក្រ- យានយន្ត | 890 | 1,380 | 1,129 |
| គ្រឿងបន្លាស់យានយន្ត | 19 | 14 | 14 |
| បរិក្ខារត្រជាក់ | 52 | 49 | 54 |
| មាស | 1,036 | 130 | 315 |
| ប្រេងឥន្ធនៈ | 1,125 | 1,215 | 1,011 |
| ជីកសិកម្ម | 76 | 129 | 186 |
| ផ្សេងៗ | 3,926 | 3,944 | 5,133 |
| **សរុប** | **10,983** | **11,280** | **12,763** |

ប្រភពៈ ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## *តារាង 9÷ ការនាំចេញមុខទំនិញសំខាន់ៗ (គិតជាបរិមាណ)*

| មុខទំនិញ | ឯកត្តា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| សម្លៀកបំពាក់ | ពាន់ឡូ | 39,687 | 43,787 | 46,684 |
| ស្បែកជើង | ពាន់គូ | 22,366 | 22,577 | 30,607 |
| វាយនភ័ណ្ឌផ្សេងៗ | ពាន់ឡូ | 3,621 | 3,139 | 2,366 |
| គ្រឿងបង្កុំអេឡិចត្រូនិច | ពាន់តោន | 0 | 0 | 4 |
| គ្រឿងបង្គុំរថយន្ត | ពាន់តោន | 0 | 0 | 0 |
| កង់ | ពាន់គ្រឿង | 0 | 0 | 511 |
| ឈើមូល | ពាន់ម៣ | 6 | 0 | 0 |
| ឈើកែច្នៃ | ពាន់ម៣ | 9 | 1 | 0 |
| ក្តាបន្ទះ | ពាន់តោន | 3 | 0 | 0 |
| ផលិតផលផ្សេងៗពីឈើ | ពាន់តោន | 2 | 6 | 16 |
| អង្ករ | ពាន់តោន | 155 | 159 | 158 |
| ស្រូវ | ពាន់តោន | 0 | 0 | 1 |
| កៅស៊ូ | ពាន់តោន | 31 | 29 | 34 |
| ស្ករស | ពាន់តោន | 0 | 0 | 15 |
| ផលិតផលជលផល | ពាន់តោន | 0 | 0 | 0 |
| ផលិតផលកសិកម្មផ្សេងៗ | ពាន់តោន | 61 | 54 | 113 |
| បារី | ពាន់តោន | 0 | 0 | 1 |
| មាស | គីឡូក្រាម | 481 | 1,055 | 0 |
| ផលិតផលផ្សេងៗ | ពាន់តោន | 429 | 243 | 193 |

*ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## *រូបភាព 6÷ ចំណែកនៃទីផ្សារនាំចេញ (គិតជាភាគរយ)*




ប្រភព: ទំនិញពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រូបភាព 7÷ ស្ថានភាពនាំចេញទៅទីផ្សារអន្តរជាតិ (គិតជាលានដុល្លារអាមេរិក)




ប្រភព: ទិន្នន័យពាណិជ្ជកម្មអន្តរជាតិឆ្លងតាមមាត់ច្រកគយពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## តារាង 10÷ មុខទំនិញនាំចេញ (គិតជាប៊ីលានរៀល)

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| សម្លៀកបំពាក់ | 5,446 | 6,275 | 6,445 |
| ស្បែកជើង | 601 | 675 | 841 |
| វាយនភ័ណ្ឌផ្សេងៗ | 202 | 175 | 168 |
| គ្រឿងបង្គុំអេឡិចត្រូនិច | 0 | 0 | 510 |
| គ្រឿងបង្គុំរថយន្ត | 0 | 0 | 7 |
| កង់ | 0 | 0 | 411 |
| ឈើមូល | 39 | 0 | 0 |
| ឈើកែច្នៃ | 5 | 0 | 0 |
| ក្តាបន្ទះ | 2 | 0 | 0 |
| ផលិតផលផ្សេងៗពីឈើ | 11 | 19 | 50 |
| អង្ករ | 360 | 367 | 334 |
| ស្រូវ | 0 | 0 | 1 |
| កៅស៊ូ | 168 | 123 | 266 |
| ស្ករស | 0 | 0 | 34 |
| ផលិតផលជលផល | 1 | 1 | 1 |
| ផលិតផលកសិកម្មផ្សេងៗ | 21 | 41 | 160 |
| បារី | 12 | 11 | 22 |
| មាស | 76 | 164 | 0 |
| ផលិតផលផ្សេងៗ | 1,812 | 1,798 | 915 |
| **នាំចេញសរុប** | **8,756** | **9,652** | **10,165** |

## ២.៧. ការវិនិយោគឯកជន

*តារាង 11 ÷ ស្ថិតិវិនិយោគវិស័យឯកជន (អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)*

| ការអនុញ្ញាតវិនិយោគដោយ (CDC) | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **គម្រោង** | ចំនួន | 37 | 37 | 21 |
| **បង្កើតការងារ** | ការងារ | 45,562 | 43,345 | 33,825 |
| **ទុនវិនិយោគលើវិស័យ** | | | | |
| កសិកម្ម | លានដុល្លារ | 271 | 38 | 8 |
| ឧស្សាហកម្ម | លានដុល្លារ | 98 | 134 | 116 |
| សេវាកម្ម | លានដុល្លារ | 2,444 | 140 | 4 |
| ទេសចរណ៍ | លានដុល្លារ | 61 | 642 | 4 |
| **សរុប** | **លានដុល្លារ** | **2,873** | **955** | **131** |

ប្រភពៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

*រូបភាព 8 ÷ ចំនួនគម្រោង និងទុនវិនិយោគ (គិតជាលានដុល្លារអាមេរិក)*




ប្រភពៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ២.៨. វិស័យទេសចរណ៍

*តារាង 12 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជាពាន់នាក់)*

| សូចនាករ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **សរុប** | **1,308** | **1,342** | **1,503** |
| តាមផ្លូវអាកាស | 733 | 785 | 921 |
| ភ្នំពេញ | 273 | 303 | 347 |
| សៀមរាប | 461 | 479 | 552 |
| កងកេង | | 2 | 0 |
| តាមផ្លូវគោក និង ផ្លូវទឹក | 574 | 557 | 581 |
| ផ្លូវគោក | 529 | 493 | 510 |
| ផ្លូវទឹក | 45 | 64 | 72 |
| **តាមប្រភេទ** | **1,308** | **1,342** | **1,503** |
| អ្នកទេសចរ | 1,190 | 1,188 | 1,353 |
| អ្នកជំនួញ | 66 | 87 | 84 |
| ផ្សេងៗ | 52 | 67 | 66 |

ប្រភព: ក្រសួងទេសចរណ៍

*រូបភាព 9 ÷ ចំនួនអ្នកដំណើរឆ្លងកាត់ប្រទេសកម្ពុជា (គិតជាពាន់នាក់) និងកំណើន (%)*




ប្រភព: ក្រសួងទេសចរណ៍

## ២.៩. វិស័យសំណង់

*តារាង 13 ÷ គម្រោងអនុញ្ញាតសាងសង់*

| | ឯកត្តា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **សំណើសុំសាងសង់** | | | | |
| គម្រោង | ចំនួន | 368 | 473 | 786 |
| ក្រឡាផ្ទៃ | ម២ | **1,412,314** | **3,799,404** | **2,073,040** |
| តម្លៃសាងសង់ | លានដុល្លារ | 445 | 1,647 | 1,282 |
| **សំណើសុំសាងសង់តាមប្រភេទ** | | | | |
| សំណង់សាធារណៈ | ម២ | 24,023 | 10,082 | 6,993 |
| ថវិការាជរដ្ឋាភិបាល | ម២ | 2,981 | 0 | 380 |
| ថវិកាវិស័យឯកជន | ម២ | 21,042 | 10,082 | 6,613 |
| លំនៅដ្ឋាន និង ភូមិគ្រឹះ | ម២ | 1,016,820 | 1,225,213 | 1,391,185 |
| សំណង់ឧស្សាហកម្ម | ម២ | 293,935 | 354,951 | 306,639 |
| សំណង់ពាណិជ្ជកម្ម | ម២ | 34,424 | 2,171,748 | 152,205 |
| សំណង់ទេសចរណ៍ | ម២ | 37,953 | 34,485 | 215,896 |
| សំណង់វិនិយោគផ្សេងៗ | ម២ | 5,159 | 2,926 | 120 |
| **សរុប** | **ម២** | **1,412,314** | **3,799,404** | **2,073,039** |

ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

*រូបភាព 10 ÷ សំណើសុំវិនិយោគសាងសង់ គិតជាក្រឡាផ្ទៃ ចែកតាមប្រភេទសំណង់*




ប្រភព: ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់

## ៣. ថ្លៃទំនិញសំខាន់ៗ និងអត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

*តារាង 14 ÷ ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក)*

| មុខទំនិញ | ឯកតា | ទីផ្សារ | ត្រីមាសទី១ | | |
|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ |
| អង្ករ | តោន/ ដុល្លារ | បាងកក | 410 | 384 | 358 |
| ឈើមូល | ម³/ ដុល្លារ | ម៉ាឡេស៊ី | 247 | 264 | 263 |
| ប្រេងឆៅ Brent | ធុង/ ដុល្លារ | ក្រុងឡុង | 56 | 39 | 52 |
| កៅស៊ូ | តោន/ ដុល្លារ | សឹង្ហបុរី | 1,735 | 1,447 | 2,350 |
| មាស | អោន/ ដុល្លារ | ហុងកុង | 1,074 | 1,366 | 1,351 |
| កប្បាស | តោន/ ដុល្លារ | ញូយ៉ក | 1,529 | 1,443 | 1,913 |
| ពោតក្រហម | តោន/ ដុល្លារ | ស៊ីកាហ្គោ | 174 | 159 | 159 |
| សណ្តែកសៀង | តោន/ ដុល្លារ | ស៊ីកាហ្គោ | 403 | 375 | 405 |
| ប្រេងដូង | តោន/ ដុល្លារ | រ៉ុតធើដាំ | 1,096 | 1,448 | 1,547 |
| ស្ករស | តោន/ ដុល្លារ | ក្រុងឡុង | 354 | 363 | 349 |

ប្រភព: គេហទំព័រធនាគារពិភពលោក

*រូបភាព 11 ÷ ថ្លៃជីកសិកម្មលើទីផ្សារអន្តរជាតិ (គិតជាដុល្លារអាមេរិក/ម៉ែត្រិកតោន)*




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

## តារាង 15 ÷ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់លើទីផ្សារអន្តរជាតិ (ឆ្នាំគោល ២០១០=១០០)

| មុខទំនិញ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ប្រេងឥន្ធនៈ | 53 | 37 | 51 |
| ផលិតផលកសិកម្ម | 91 | 86 | 89 |
| ម្ហូបអាហារ | 94 | 88 | 93 |
| ឈើ | 95 | 92 | 83 |
| ជីគីមី | 96 | 77 | 76 |

ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

## រូបភាព 12 ÷ សន្ទស្សន៍ថ្លៃមុខទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ




ប្រភព: គេហទំព័រធនាគារពិភពលោក (http://www.worldbank.org/en/research/commodity-markets)

## តារាង 16 ÷ អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិធៀបនឹងដុល្លារអាមេរិក (មធ្យមប្រចាំត្រីមាស)

| រូបិយប័ណ្ណ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ជប៉ុន (យ៉េន) | 119.39 | 112.47 | 116.72 |
| ហុងកុង (ដុល្លារ) | 7.75 | 7.75 | 7.75 |
| សឹង្ហបុរី (ដុល្លារ) | 1.37 | 1.35 | 1.45 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.71 | 3.93 | 4.48 |
| ហ្វីលីពីន (ប៉េសូ) | 44.71 | 45.98 | 49.48 |

| រូបិយប័ណ្ណ | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| ថៃ (បាត) | 32.53 | 35.19 | 35.76 |
| ឥណ្ឌូនេស៊ី (រូពា) | 13,037.80 | 13,192.60 | 13,440.90 |
| កូរ៉េ (វ៉ុន) | 1,104.97 | 1,147.05 | 1,203.51 |
| តៃវ៉ាន់ (ដុល្លារ) | 31.20 | 32.33 | 32.32 |
| ចិន (រ៉េនមីនប៊ី) | 6.11 | 6.46 | 6.95 |
| កម្ពុជា (រៀល) | 4,016.00 | 3,929.60 | 3,928.39 |
| ឡាវ (គីប) | 7,920.62 | 7,928.17 | 7,908.57 |
| វៀតណាម (ដុង) | 21,199.60 | 21,989.00 | 22,437.90 |
| ឥណ្ឌា (រូពី) | 62.53 | 66.14 | 67.84 |
| រុស្ស៊ី (រូប) | 57.81 | 68.06 | 60.80 |
| អូស្ត្រាលី (ដុល្លារ) | 1.30 | 1.31 | 1.38 |
| មិចស៊ិចកូ (ប៉េសូ) | 15.23 | 17.27 | 20.67 |
| អង់គ្លេស (ផោន) | 0.67 | 0.69 | 0.81 |
| ស្វីស (ហ្វ្រង់) | 0.96 | 0.96 | 1.02 |
| អឺរ៉ុប (អឺរ៉ូ) | 0.92 | 0.88 | 0.95 |

ប្រភព: OANDA (Internet)

# ឧបសម្ព័ន្ធ

*តារាង 17÷ ថ្លៃទំនិញនិងសេវាលើទីផ្សារភ្នំពេញ (គិតជាដុល្លារអាមេរិក)*

| ល.រ | ឈ្មោះទំនិញ | ប្រភេទ | ឯកត្តា | ត្រីមាសទី១ | |
|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ |
| ក-សម្ភារសំណង់ (ថ្លៃជាមធ្យម) | | | | | |
| 1 | ឥដ្ឋតាន់ | អង្គរ | ១០,០០០ដុំ | 360.0 | 325.0 |
| 2 | ស៊ីម៉ងតិ៍ | ដំរី | តោន | 102.0 | 98.0 |
| 3 | ដែកកង | ៩លី | តោន | 450.0 | 515.0 |
| 4 | ខ្សាច់ | ត្រើម | ១គូប | 14.0 | 10.0 |
| 5 | ស័ង្កសីពាស៊ីស | ពាម | សន្លឹក | 4.2 | 4.2 |
| 6 | ស្លេចត្រូក្រៅ | U៩០ | ធុង/២៥គក្រ | 51.0 | 52.0 |
| ខ-កុំព្យូទ័រ និងឧបករណ៍ភ្ជាប់កុំព្យូទ័រ (ថ្លៃជាមធ្យម) | | | | | |
| 7 | Hard DiskTranscend Portable 25D3 (1TB) | Transcend | គ្រឿង | 62.0 | 49.0 |
| 8 | Hard Disk Transcend Portable 25D3 (750GB) | Transcend | គ្រឿង | 60.0 | 47.0 |
| 9 | Hard Disk Transcend Portable 25D3 (500GB) | Transcend | គ្រឿង | 56.0 | 43.0 |
| 10 | PC Desktop HP Elite Desk (CORE I5) | HP | គ្រឿង | 736.0 | 823.0 |
| 11 | Laptop (CORE i5-i7) | HP | គ្រឿង | 639.0 | 735.0 |
| 12 | Printer Laserjet | HP | គ្រឿង | 568.0 | 565.0 |
| គ-ប្រេងរំអិលរថយន្ត (ថ្លៃជាមធ្យម) | | | | | |
| 13 | តម្រងប្រេងម៉ាស៊ីន | ជប៉ុន | គ្រឿង | 7.0 | 7.4 |
| 14 | ប្រេងរំអិលម៉ាស៊ីនរថយន្ត | ម៉ាស៊ីនម៉ាស៊ូត | ចំនុះ ៥ លីត្រ | 26.0 | 32.4 |
| 15 | ប្រេងរំអិលម៉ាស៊ីនរថយន្ត | ម៉ាស៊ីនម៉ាស៊ូតនិងសាំង | | 32.0 | 52.0 |
| 16 | ប្រេងរំអិលម៉ាស៊ីនម៉ាស៊ូត | B 40 TOT SG | ធុងចំនុះ ២០៨ លីត្រ | 620.0 | 612.6 |
| 17 | ប្រេងរំអិលម៉ាស៊ីនម៉ាស៊ូត | B 50 TOT SG | ធុងចំនុះ ២០៨ លីត្រ | 620.0 | 612.6 |
| 18 | ប្រេងរំអិលម៉ាស៊ីនម៉ាស៊ូត | C 50 TOT SG | ធុងចំនុះ ២០៨ លីត្រ | 630.0 | 622.4 |
| 19 | ប្រេងរំអិលម៉ាស៊ីនម៉ាស៊ូត/ សាំង | S 40 208L TOT SG | ធុងចំនុះ ២០៨ លីត្រ | 650.0 | 642.0 |
| 20 | ប្រេងបូមចង្កូត និងប្រេងប្រអប់លេខស្វ័យប្រវត្តិ (FLUIDMATIC IID 18B1L TOT SG) | ១លីត្រ | ធុង | 7.0 | 11.3 |
| 21 | ប្រេងហ្វ្រាំង | 0,៥ លីត្រ | ធុង | 7.0 | 7.7 |
| 22 | ថ្នាំធុងទឹកត្រជាក់ លាយស្រេច | ៤ លីត្រ | ធុង | 25.0 | 31.5 |
| 23 | ថ្នាំធុងទឹកត្រជាក់ លាយស្រេច | ១ លីត្រ | ធុង | 8.0 | 8.1 |
| ឃ-ម៉ាស៊ីនត្រជាក់ និងទូទឹកកក | | | | | |
| ឃ1-ម៉ាស៊ីនត្រជាក់ (ថ្លៃជាមធ្យម) | | | | | |
| 24 | 1.0 Horse Power | សំចៃភ្លើង | គ្រឿង | 380.0 | 430.0 |
| 25 | 1.0 Horse Power | ប្រព័ន្ធធម្មតា | គ្រឿង | 260.0 | 300.0 |
| ឃ2-ទូទឹកកក (ថ្លៃជាមធ្យម) | | | | | |
| 26 | ទូទឹកកកទ្វារពីរ ខ្នាតមធ្យម | សំចៃភ្លើង | គ្រឿង | 355.0 | 400.0 |
| 27 | ទូទឹកកកទ្វារពីរ ខ្នាតធំ | សំចៃភ្លើង | គ្រឿង | 470.0 | 550.0 |

| ល.រ | ឈ្មោះទំនិញ | ប្រភេទ | ឯកត្តា | ត្រីមាសទី១ | |
|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ |
| ង- តុ ទូ និងកៅអី (ថ្លៃជាមធ្យម) | | | | | |
| 28 | កៅអីការិយាល័យដែកមានពូក | ចិន | គ្រឿង | 115.0 | 120.0 |
| 29 | កៅអីការិយាល័យជ័រមានពូក | ចិន | គ្រឿង | 90.0 | 90.0 |
| 30 | ទូដែកឈរដាក់ឯកសារដាក់ឯកសារជាក្រូណូ | ថៃ | គ្រឿង | 230.0 | 220.0 |
| 31 | តុការិយាល័យដែក មានកញ្ចក់ពីលើ (តម្លៃអាស្រ័យលើម៉ាក និងខ្នាត) | | គ្រឿង | 340.0 | 330.0 |
| ច- ទូរសព្ទដៃ (ថ្លៃជាមធ្យម) | | | | | |
| 32 | ទូរសព្ទដៃ | Nokia 105 Dual Sim 2 | គ្រឿង | 23.0 | 22.0 |
| 33 | ទូរសព្ទដៃ | SAMSUNG Galxy 6S Edge Plus | គ្រឿង | 775.0 | 550.0 |
| 34 | ទូរសព្ទដៃ | Sony Xperia M5 | គ្រឿង | 370.0 | 300.0 |
| 35 | ទូរសព្ទដៃ | LG Optimus G | គ្រឿង | 210.0 | 150.0 |
| 36 | ទូរសព្ទដៃ | iPhone 6s 16GB | គ្រឿង | 705.0 | 430.0 |
| ឆ- សម្ភារៈការិយាល័យ (ថ្លៃជាមធ្យម) | | | | | |
| 37 | ទឹកខ្មៅ | XP 5100 | ប្រអប់ | 80.9 | 90.0 |
| 38 | ក្រណាត់ធំ | រូបស្មាំង | គ្រឿង | 1.7 | 1.5 |
| 39 | ក្រដាសរ៉ាម A4 Double A | 80g | រ៉ាម | 3.7 | 3.6 |
| 40 | ក្រដាសរ៉ាម A4 Double A | 70g | រ៉ាម | 3.0 | 3.2 |
| 41 | ក្រដាសរ៉ាម A4 Idea | | រ៉ាម | 3.6 | 3.1 |
| 42 | ប៊ិច UNIBALL | ជប៉ុន | ដើម | 0.8 | 1.3 |
| 43 | ទឹកខ្មៅព្រីនធ័រ | Laser 6L,5L | ប្រអប់ | 63.0 | 72.0 |
| ជ- សំបុត្រយន្តហោះ (ថ្លៃជាមធ្យម) | | | | | |
| 44 | ភ្នំពេញ- សឹង្ហបុរី- ភ្នំពេញ | MI | ៤៥ថ្ងៃ | 418.0 | 500.5 |
| 45 | ភ្នំពេញ- បាងកក- ភ្នំពេញ | PG | ១ខែ | 325.0 | 302.5 |
| 46 | ភ្នំពេញ- ហុងកុង- ភ្នំពេញ | KA | ១ខែ | 715.0 | 649.0 |
| 47 | ភ្នំពេញ- អូសាកា- ភ្នំពេញ | BR | ៣ខែ | 1,029.0 | 825.0 |
| 48 | ភ្នំពេញ- ហាណូយ- ភ្នំពេញ | VN | ៣ខែ | 493.0 | 528.5 |

## *តារាង 18 ៖ ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល (GFS)*

| លានរៀល | ត្រីមាសទី១ | | |
|---|---|---|---|
| | ២០១៥ | ២០១៦ | ២០១៧ |
| **ចំណូល (១)** | **2,772,190** | **3,645,025** | **4,393,553** |
| ពន្ធ | 2,416,245 | 3,261,569 | 3,906,527 |
| អំណោយ | 139,327 | 135,497 | 150,197 |
| ចំណូលពន្ធផ្សេងទៀត | 216,617 | 247,959 | 336,829 |
| **ចំណាយ (២)** | **1,437,164** | **1,644,453** | **2,116,607** |
| បៀវត្សនិងលាភបការ | 825,747 | 956,465 | 1,347,738 |
| ទំនិញ និងសេវាកម្ម | 220,871 | 143,871 | 150,226 |
| ការប្រាក់ | 76,434 | 109,870 | 109,105 |
| អំណោយ | 154,724 | 192,774 | 199,680 |
| ឧបត្ថម្ភសង្គមកិច្ច | 125,952 | 196,397 | 237,779 |
| ចំណាយផ្សេងៗ | 33,436 | 45,076 | 72,078 |
| **តុល្យភាពប្រតិបត្តិការសុទ្ធ (២)-(៣)** | **1,335,025** | **2,000,572** | **2,276,946** |
| **ទ្រព្យមិនមែនហិរញ្ញវត្ថុសុទ្ធ (៣)** | **658,914** | **719,806** | **1,010,029** |
| ទ្រព្យអចលកម្ម | 636,924 | 713,344 | 1,007,193 |
| ទ្រព្យគ្មានផលិតភាព | 21,990 | 6,462 | 2,837 |
| ***កម្ចី/បំណុលសុទ្ធ (១)-(២)-(៣)*** | 676,112 | 1,280,765 | 1,266,917 |
| **ទ្រព្យហិរញ្ញវត្ថុសុទ្ធ** | **1,325,531** | **409,275** | **1,358,927** |
| ក្នុងប្រទេស | 1,325,531 | 409,275 | 1,358,927 |
| **បំណុល** | **(84,644)** | **(414,428)** | **104,467** |
| ក្នុងប្រទេស | (323,800) | (544,462) | (403,133) |
| ក្រៅប្រទេស | 239,155 | 130,034 | 507,600 |

*ប្រភព: អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## តារាង 19 ÷ ស្ថិតិកសិកម្ម

| ផលិតកម្មកសិកម្ម និងនាំចេញ | ឯកតា | ត្រីមាសទី១ | | |
|---|---|---|---|---|
| | | ២០១៥ | ២០១៦ | ២០១៧ |
| **ផ្ទៃដីដាំដុះ** | | | | |
| ស្រូវ | ហិកតា | 3,055,507 | 3,051,412 | 3,118,160 |
| ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម | ហិកតា | 901,741 | 956,272 | 1,030,596 |
| កៅស៊ូ | ហិកតា | 243,370 | 388,681 | 435,991 |
| **ផ្ទៃដីប្រមូលផល** | | | | |
| ស្រូវ | ហិកតា | 2,979,914 | 3,025,430 | 3,097,253 |
| កៅស៊ូ | ហិកតា | 90,545 | 111,016 | 129,666 |
| **បរិមាណផល** | | | | |
| ស្រូវ | តោន | 9,058,720 | 9,232,088 | 9,926,816 |
| កៅស៊ូ (ក្រែប) | តោន | 26,261 | 33,309 | 36,788 |
| ជលផល | តោន | 168,455 | 136,450 | 149,698 |
| **នាំចេញ** | | | | |
| អង្ករ | តោន | 154,914 | 159,168 | 157,620 |
| ស្រូវ | តោន | - | - | 850 |
| កៅស៊ូ | តោន | 31,013 | 28,992 | 34,130 |
| ស្ករ | តោន | - | - | 14,600 |
| ផលិតផលជលផល | តោន | 84 | 47 | 60 |
| ផលិតផលកសិកម្មផ្សេងៗ | តោន | 60,977 | 54,484 | 113,063 |

ប្រភព: របាយការណ៍ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំឆ្នាំ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
របាយការណ៍ ពាណិជ្ជកម្មប្រចាំខែ

## កំណត់សម្គាល់បច្ចេកទេស

| | |
|---|---|
| **មុខទំនិញនិងសេវាលើទីផ្សារភ្នំពេញ** | មុខទំនិញទាំងអស់ ត្រូវបានចែកចេញជា ១០ ក្រុម រួមមាន សម្ភារការិយាល័យ សម្ភារសំណង់ គ្រឿងសង្ហារឹម ឧបករណ៍អេឡិចត្រូនិច សម្ភារបរិក្ខារអគ្គិសនី សម្ភារប្រើប្រាស់និងសម្អាត សម្ភារប្រើប្រាស់ផ្សេងៗ យានយន្តនិងគ្រឿងបន្លាស់ ថ្នាំពេទ្យនិងបរិក្ខារពេទ្យ និងសំបុត្រយន្តហោះ។ |
| **ចំណូល (ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល)** | ជាប្រតិបត្តិការ ដែលធ្វើឱ្យតម្លៃទ្រព្យសកម្មសុទ្ធកើនឡើង។ ប្រតិបត្តិការចំណូលនៅក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល អាចធ្វើឱ្យមានការកើនឡើងនៃទ្រព្យ ឬការថយចុះនៃបំណុល និងអាចឱ្យមានការប្រែប្រួលកំណើននៃតំលៃទ្រព្យសកម្មសុទ្ធ។ |
| **ចំណាយ (ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល)** | គឺជាប្រតិបត្តិការ ដែលធ្វើឱ្យតម្លៃទ្រព្យសកម្មសុទ្ធថយចុះ។ ប្រតិបត្តិការចំណាយក្នុងស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ធ្វើឱ្យមានផលប៉ះពាល់ពីរធំៗ រួមមាន ការថយចុះនៃទ្រព្យឬការកើនឡើងនៃបំណុល។ |

## ក្រុមការងារព្រឹត្តិបត្រ

| **ឈ្មោះ** | **ទទួលបន្ទុក** |
|---|---|
| លោក ឃឹម ហ្វាដាណេ | ដឹកនាំ និងទទួលបន្ទុកការងាររួម |
| លោក ស្រៀង ចន្នី | សកម្មភាពវិនិយោគ និងសំណង់ |
| លោក ផៃ ពុទ្ធី | សកម្មភាពទេសចរណ៍ |
| លោក ស្រេង សោភ័ណរស្មី | តារាងប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (TOFE) |
| លោក យ៉ន សម្បត្តិ | ស្ថិតិហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល (GFS) |
| លោក នី សុផានិត | អតិផរណា |
| លោក ខៀ សុខលាភ | អត្រាប្តូរប្រាក់ក្នុងស្រុកនិងក្រៅស្រុក និងថ្លៃទំនិញលើទីផ្សារអន្តរជាតិ |
| លោក យន សារ៉ែន | អង្កេតរូបិយវត្ថុ និងពាណិជ្ជកម្មទំនិញអន្តរជាតិ |
| លោក ហេង បណ្ឌូល | សកម្មភាពកសិកម្ម |
| លោកស្រី ឃុន មារតី | អង្កេតថ្លៃទំនិញទីផ្សារ និងទិន្នន័យគាំទ្រផ្សេងទៀត |

*ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយក្រុមការងារព្រឹត្តិបត្រ នៃនាយកដ្ឋានស្ថិតិ និងត្រួតពិនិត្យពិភាក្សាក្នុងក្រុមការងាររបស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។*